ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខៈ ២៤៤/១៧ គ.ជ.ប.ជ

# របាយការណ៍បូកសរុបសកម្មភាព
# និងលទ្ធផលការងារបង្ការ-ទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរមនុស្ស
# និងអំពើធ្វើអាជីវកម្មផ្លូវភេទ ប្រចាំខែវិច្ឆិកា និងទិសដៅខែធ្នូ ឆ្នាំ២០១៧

## I. ស្ថានភាពទូទៅ

ក្នុងខែវិច្ឆិកា ឆ្នាំ២០១៧ ស្ថានភាពបទល្មើសជួញដូរមនុស្ស ត្រូវបានរកឃើញ និងបង្ក្រាបជាបន្តបន្ទាប់គួរឲ្យកត់សម្គាល់។ ដោយឡែកការធ្វើចំណាកស្រុកឆ្លងដែន ឬទេសន្តរប្រវេសន៍ ក៏មានស្ថានភាពមិនប្រក្រតីដែលមានប្រជាពលរដ្ឋចាកចេញទៅធ្វើការនៅប្រទេសថៃរហូតដល់ជាងមួយលាននាក់ ទាំងស្របច្បាប់ ទាំងមិនមានឯកសារច្បាប់។ ថ្មីៗនេះ រាជរដ្ឋាភិបាលថៃ បានចេញគោលការណ៍រឹតបន្តឹងពលករទេសសន្តប្រវេសន៍ ដែលរស់នៅ និងធ្វើការខុសច្បាប់ក្នុងប្រទេសថៃ។ ដើម្បី ជាដំណោះស្រាយ រដ្ឋាភិបាលថៃបានទុករយៈពេល៦ខែ ពីខែមិថុនា ដល់ចុងខែធ្នូ ឆ្នាំ២០១៧ ដើម្បីឲ្យពលកររៀបចំបំពេញបែបបទឯកសារស្របច្បាប់ ជាពិសេសលិខិតឆ្លងដែន ឲ្យទាន់ពេលវេលា ពុំនោះទេពលករទាំងនោះនឹងត្រូវបញ្ជូនត្រឡប់មកប្រទេសដើមវិញ។ រាជរដ្ឋាភិបាលកម្ពុជាបានបញ្ជូនក្រុមការងារផ្តល់ភាពស្របច្បាប់ ជូនពលករ ជិតបួនរយនាក់ ដើម្បីផ្តល់លិខិតឆ្លងដែន និងសម្រួលការបំពេញបែបបទស្របច្បាប់ នៅទីក្រុងបាងកក ខេត្តរ៉ៃយ៉ង ឆាកធឹងសាវ និងប៉ាធុមថានី ដើម្បីពន្លឿនការទទួលបានភាពស្របច្បាប់ដល់ពលករកម្ពុជា។

មិនតែប៉ុណ្ណោះការខិតខំប្រឹងប្រែងរបស់ប្រមុខរាជរដ្ឋាភិបាលដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានបញ្ជាក់ថា៖ ១. រាជរដ្ឋាភិបាល បាននិងកំពុងអនុវត្តសេចក្តីថ្លែងការណ៍អាស៊ាន ស្តីពីការការពារ និងលើកកម្ពស់ សិទ្ធិពលករទេសន្តប្រវេសន៍ តាមរយៈខិតខំជួយពលករ ដែលធ្វើការនៅបរទេស ដើម្បីធានាបាននូវផលប្រយោជន៍ស្របច្បាប់ និងជួយផ្តល់ភាពស្របច្បាប់ដល់ពលករ ។ ២. រាជរដ្ឋាភិបាលកំពុងសហការជាមួយប្រទេសជាដៃគូ ទទួលស្គាល់ពលករដែលមានជំនាញទៅវិញទៅមក ជាមួយកម្ពុជា ។ ៣. រាជរដ្ឋាភិបាលកំពុងសហការជាមួយបណ្តាប្រទេសអាស៊ាន ក្នុងកិច្ចសហប្រតិបត្តិការ លើវិស័យរបបសន្តិសុខសង្គម ដោយធានាចំពោះពលករស្របច្បាប់នៅគ្រប់ប្រទេសនៅពេលមានគ្រោះថ្នាក់ដល់ជីវិត ឲ្យទទួលបានសំណងតាមច្បាប់។ ពលករទាំងអស់អាចផ្ទេរប្រាក់ធានារ៉ាប់រងសង្គម គ្រោះថ្នាក់ការងារ និងប្រាក់ធានារ៉ាប់រងសុខភាពមកក្រុមគ្រួសារពលករនៅស្រុកកំណើត។ ៤. រាជរដ្ឋាភិបាលកំពុងសហការជាមួយបណ្តាប្រទេសអាស៊ាន ក្នុងការអនុវត្តរបបសោធន៍និវត្តន៍ ដោយពលករអាចផ្ទេរសមាជិកភាព អតីតភាពការងារ និងការបង់វិភាគទាន បេឡាជាតិរបបសន្តិសុខសង្គមពីប្រទេសមួយ បន្ទាប់ពីបានបញ្ចប់កិច្ចសន្យាការងារ ដើម្បីធ្វើជាមូលដ្ឋានគិតប្រាក់សោធននិវត្តន៍ ហើយផលប្រយោជន៍ទាំងនោះពលករនឹងទទួលបាននៅឆ្នាំ២០១៩។ ៥. រាជរដ្ឋាភិបាលកំពុងសម្រួលបែបបទជូនពលករ

នៅបរទេស អាចផ្ទេរសិទ្ធិជូនគ្រួសារ នៅក្នុងប្រទេសឲ្យធ្វើជាតំណាង ដើម្បីស្នើសុំលិខិតថ្កោលទោស លិខិតរដ្ឋបាល ឬលិខិតបញ្ជាក់អត្តសញ្ញាណផ្ទាល់ខ្លួន ដោយពុំចាំបាច់ឲ្យសាមីខ្លួនវិលត្រលប់មកស្រុកកំណើតវិញ។ ដោយឡែកសម្រាប់ពលករធ្វើការនៅប្រទេសថៃត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ឯកសារថតចម្លងត្រឹមត្រូវតាម ច្បាប់ដើម ដើម្បីបំពេញបែបបទស្របច្បាប់។ ទាំងនេះ គឺជាអត្ថប្រយោជន៍សម្រាប់ពលករទេសន្តរប្រវេសន៍ ។

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានអគ្គលេខាធិការដ្ឋាន **គ.ជ.ប.ជ** ជាសេនាធិការ បានបន្តសម្របសម្រួល ពង្រឹងកិច្ចសហការជាមួយដៃគូជាតិ និងអន្តរជាតិពាក់ព័ន្ធ ប្រមូលផ្តុំកម្លាំងចូលរួមរបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព រាជធានី-ខេត្ត ដើម្បីបង្កើនកិច្ចខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរកដំណោះស្រាយបញ្ហាប្រឈមនានា។ របាយការណ៍ដែលអគ្គលេខាធិការដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សទទួលបាន ៖

- ពីបណ្តាក្រសួង ស្ថាប័ន ថ្នាក់ជាតិ មានក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ក្រុមការពាជនរងគ្រោះ) ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) អគ្គនាយកដ្ឋានអន្តោប្រវេសន៍ កងរាជអាវុធហត្ថលើផ្ទៃប្រទេស។
- សម្រាប់បណ្តាស្ថាប័ន ថ្នាក់ក្រោមជាតិ មានលេខាធិការដ្ឋាន**២៥**រាជធានី-ខេត្ត បានផ្តល់របាយការណ៍គ្រប់ចំនួន ។

ជាលទ្ធផល ដែលសម្រេចបានក្នុងខែវិច្ឆិកា ឆ្នាំ២០១៧នេះ មានដូចខាងក្រោម៖

## II. ការអនុវត្តតាមផែនការយុទ្ធសាស្ត្រសកម្មភាពជាតិ (២០១៤-២០១៨)

### ក. ពង្រឹងការអនុវត្តច្បាប់ គោលនយោបាយ និងលើកកម្ពស់សហប្រតិបត្តិការ

#### ក.១ ការងារច្បាប់ និងគោលនយោបាយជាតិ

##### ក.១.១-កិច្ចការច្បាប់

- **លិខិតបទដ្ឋានដែលកំពុងរៀបចំ**
  - សេចក្តីព្រាងច្បាប់ ស្តីពី "**ការគ្រប់គ្រងការពពោះជំនួស**" (ក្រសួងកិច្ចការនារី)
  - សេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តិ "**សម្រាប់អនុវត្តល័ក្ខខ័ណ្ឌការងារកម្មករការងារផ្ទះ**" (ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ)
  - សេចក្តីព្រាងគោលនយោបាយ ស្តីពី "**កិច្ចការការពារកុមារតាមសាលារៀន**" (ក្រសួងអប់រំ យុវជន និងកីឡា)
  - **ក្រសួងយុត្តិធម៌** បានរៀបចំសេចក្តីព្រាងសន្ធិសញ្ញា និងកំពុងពិភាក្សារួមមាន៖
    - សេចក្តីព្រាងសន្ធិសញ្ញា ស្តីពី"**ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ**" **(ច្បាប់ជាតិ)**
    - សេចក្តីព្រាងសន្ធិសញ្ញា ស្តីពី"**ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ**" រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតឡាវ សាធារណរដ្ឋកូរ៉េ រដ្ឋាភិបាលបារាំង និងរដ្ឋាភិបាលរុស្ស៊ី។
    - សេចក្តីព្រាងសន្ធិសញ្ញា ស្តីពី"**បត្យាប័ន**"រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលឥណ្ឌា។
    - សេចក្តីព្រាង កិច្ចព្រមព្រៀង ស្តីពី "**បញ្ជូនទណ្ឌិត**" រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលអង់គ្លេស រដ្ឋាភិបាលប៉េរូ សាធារណរដ្ឋប្រជាមានិតឡាវ និងរដ្ឋាភិបាលរុស្ស៊ី និង
    - សេចក្តីព្រាងច្បាប់ ស្តីពី "**ការប្រឆាំងអំពើរត់ពន្ធមនុស្ស**"។

ក.១.២-លិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធ

- **ក្រសួងយុត្តិធម៌**បានអនុម័ត បញ្ចូលឯកសារបណ្ដុះបណ្ដាល ស្ដីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរបស់អាស៊ានសម្រាប់ព្រះរាជអាជ្ញា និងតុលាការ ដើម្បីដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សារបស់រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ។

ក.១.៣-អនុស្សរណៈ

❖ អនុស្សរណៈដែលបានចុះហត្ថលេខា

- **ប្រមុខរាជរដ្ឋាភិបាលកម្ពុជា និងប្រមុខរដ្ឋាភិបាលអាស៊ាន** បានចុះហត្ថលេខារួមគ្នាលើកិច្ចព្រមព្រៀងការពារពលករចំណាកស្រុក អាស៊ាន ស្ដី"**ពីម្ចាស់ប្រទេសបញ្ជូន និងទទួលយកពលករក្នុងតំបន់អាស៊ាន**" នៅប្រទេសហ្វីលីពីន (ថ្ងៃទី១៣-១៤ ខែវិច្ឆិកា ឆ្នាំ២០១៧)។

❖ អនុស្សរណៈកំពុងរៀបចំ

- **គណៈកម្មាធិការជាតិ គ.ជ.ប.ជ** ត្រៀមចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាជាមួយប្រទេសឥណ្ឌា ស្ដីពី "**កិច្ចសហប្រតិបត្តិការបង្ការ ទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរមនុស្ស**"។
- **ក្រសួងទេសចរណ៍** ត្រៀមចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា ស្ដីពីការអនុវត្តគម្រោងកុមារភាពជាមួយអង្គការ Friends International។

## ខ.ការបង្ការទប់ស្កាត់

### ខ.១-កាត់បន្ថយភាពរងគ្រោះដល់ជនមុខសញ្ញារងគ្រោះ៖

ប៉ុស្ដិ៍ច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ ចំនួន**០៥** គឺប៉ុស្ដិ៍ប៉ោយប៉ែត, អូរស្មាច់, ដូង, ជាំ និងប៉ុស្ដិ៍ព្រំ បានជួយសម្រួល និងផ្ដល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ ចំនួន**១៨.៦៣៤**ក្បាល ដល់ពលរដ្ឋខ្មែរដែលរស់នៅក្នុងខេត្តជាប់ព្រំដែន (**របាយការណ៍អគ្គនាយកដ្ឋានអន្តោប្រវេសន៍**)។

### ខ.២-ការអប់រំ ផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ វេទិកាសាធារណៈ

ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អាជ្ញាធរ និងសមត្ថកិច្ចពាក់ព័ន្ធ សហការជាមួយអង្គការដៃគូ បានធ្វើការផ្សព្វផ្សាយ ស្ដីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងវេទិកាសាធារណៈនៃការអនុវត្តគោលនយោបាយ "**ភូមិ-ឃុំមានសុវត្ថិភាព**" ដល់អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋបានចំនួន**៥.៨៨៨**លើក ដែលមានអ្នកចូលរួមសរុបចំនួន**៥៣៣.៥៥០**នាក់ (បើប្រៀបធៀបនឹងខែមុន មានចំនួនត្រឹមតែ**៤៤៧.៣០៩**នាក់) កើនឡើង**៨៦.២៤១**នាក់ ស្មើនឹង**១៩.២៧%** ក្នុងនោះស្ត្រីមានចំនួន**២៥៣.៨៨៥**នាក់។ (**ឧបសម្ព័ន្ធទី១**)

### ខ.៣-ការផ្សព្វផ្សាយតាមរយៈសម្ភារៈ និងតាមប្រព័ន្ធព័ត៌មាន

- **លេខាធិការដ្ឋាន គ.ខ.ប.ជ** បានផ្សព្វផ្សាយតាមវិទ្យុ ក្រោមប្រធានបទទាក់ទងនឹងអំពើជួញដូរមនុស្សចំនួន**២៤**លើក **មានខេត្ត៖** (កំពត០៨លើក សៀមរាប០៤លើក និងកោះកុង**៣៩**លើក)។
- **ខេត្តបាត់ដំបង៖ អង្គការសាម៉ារីតាន់** ចែកខិត្តប័ណ្ណផ្សព្វផ្សាយ ស្ដីពីការធ្វើចំណាកស្រុកដល់ជនចំណាកស្រុកចំនួន**១០០**នាក់។
- **ខេត្តកំពង់ចាម៖** អង្គការចាប់ដៃ បានធ្វើការជ្រើសរើសអ្នកតាមដានស្ដាប់កម្មវិធីវិទ្យុ និងចែកប័ណ្ណជំនួយ**៥០០**សន្លឹក ដល់ប្រជាពលរដ្ឋ។

### ខ.៤-ទប់ស្កាត់ រារាំងតម្រូវការសេវាកម្ម ដែលទំនោរទៅរកការជួញដូរមនុស្ស

#### ខ.៤.១-<u>វិធានការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្ស ក្នុងគោលដៅបម្រើសេវាកម្មផ្លូវភេទ</u>៖

ក្នុងខែវិច្ឆិកា ឆ្នាំ២០១៧នេះ អគ្គស្នងការដ្ឋាននគរបាលជាតិ (របាយការណ៍ពីក្រុមការងារអនុវត្តន៍ច្បាប់) និងស្នងការរាជធានី-ខេត្ត បានសហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាពបង្ការទប់ស្កាត់តាមគោលដៅ ទទួលបានលទ្ធផលដូចខាងក្រោម ៖

- ស្រង់ស្ថិតិ ទិន្នន័យ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ញារកម្ម និងផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់ម្ចាស់អាជីវកម្ម និងបុគ្គលិក ធ្វើការក្នុងហាងម៉ាស្សា ខារ៉ាអូខេ បានចំនួន**៤៥៦**គោលដៅ មានមនុស្សចំនួន**១.១១៦**នាក់ (ស្រី **៩០០**នាក់) **កម្លាំងជំនាញអនុវត្ត នៃស្នងការដ្ឋាននគរបាលខេត្ត មាន៖** (តាកែវ កណ្តាល កែប កំពត មណ្ឌលគិរី រតនគិរី ស្វាយរៀង និងកំពង់ឆ្នាំង)។
- គោលដៅសង្ស័យប្រព្រឹត្តបទល្មើសជួញដូរមនុស្ស និងការធ្វើអាជីកម្មផ្លូវភេទ ក្នុងនោះអំពើជួញដូរមនុស្ស ចំនួន០៩គោលដៅ និងអំពើធ្វើអាជីវកម្មផ្លូវភេទចំនួន**៦៦**គោលដៅ សរុបចំនួន**៧៥**គោលដៅ ទូទាំងរាជធានី-ខេត្ត។
- ការល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទ ធ្វើបានចំនួន**២៣**លើក ក្នុងនោះ ខេត្តដែលអនុវត្តមាន៖ ស្វាយរៀង កំពង់ស្ពឺ និងពោធិ៍សាត់។

### ខ.៥.គោលនយោបាយប្រឆាំងនឹងទេសន្តរប្រវេសន៍ខុសច្បាប់ និងគ្រោះថ្នាក់

#### ខ.៥.១. <u>វិធានការគ្រប់គ្រងបច្ចុប្បន្នភាពចំណាកស្រុក</u>

- ***បច្ចុប្បន្នភាពស្ថិតិចំណាកស្រុក***

បច្ចុប្បន្នភាពទិន្នន័យពលករចំណាកស្រុកទៅក្រៅប្រទេស បានពិនិត្យឃើញថា នៅតែបន្តកើតមានឡើង ជាក់ស្តែងក្នុងខែវិច្ឆិកា ឆ្នាំ២០១៧នេះ តួលេខមានដូចក្នុងតារាងខាងក្រោម៖

***តារាងតាមដានបច្ចុប្បន្នភាពទិន្នន័យពលករខ្មែរចំណាកស្រុក ប្រចាំខែវិច្ឆិកា***

| ប្រចាំខែ | សរុបរួម | | | | ស្របច្បាប់ | | | | មិនស្របច្បាប់ | | | | សម្គាល់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | សរុប | ស្រី | អនីតិជន | | សរុប | ស្រី | អនីតិជន | | សរុប | ស្រី | អនីតិជន | | |
| | | | សរុប | ស្រី | | | សរុប | ស្រី | | | សរុប | ស្រី | |
| វិច្ឆកា | ៣២០.៩៥១ | ១៤០.៦២០ | ៨.៩៥៩ | ៣.៣៧៣ | ១៧៨.៨៩៣ | ៨៣.៨៣៦ | ១.១៤០ | ៥២៤ | ១៤២.០៥៨ | ៥៦.៧៨៤ | ៧.៨១៩ | ២.៨៤៩ | កើនឡើង ៥.៣៩០ |

#### ខ.៥.២ <u>ការតាមដានស្ថិតិពលករ ដែលត្រូវបានចាប់បញ្ជូនដោយអាជ្ញាធរបរទេសតាមច្រកព្រំដែន</u>

- **អគ្គនាយកដ្ឋានអន្តោប្រវេសន៍** បានទទួលពលរដ្ឋខ្មែរដែលអាជ្ញាធរបរទេសបញ្ជូនត្រឡប់មកវិញ ចំនួន១៨៨លើក មនុស្សចំនួន៤.៤៤៨នាក់ (ស្រី**១.៥២៧**នាក់ និងកុមារ**៤៥៥**នាក់) ក្នុងនោះតាមច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិចំនួន២២លើក មនុស្សចំនួន៤៥នាក់ ស្រី២១នាក់ តាមច្រកទ្វារព្រំដែនកម្ពុជា-ថៃចំនួន**១៦៥**លើក មនុស្សចំនួន៤.៤០២នាក់ (ស្រី**១.៥០៥**នាក់ កុមារ៤៥៥នាក់) និងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិបាវិតចំនួន**០១**លើក មនុស្សចំនួន០១នាក់(ស្រី)។

***<u>ស្ថានភាព៖</u>***

❖ **ក្រុមអនុវត្តន៍ច្បាប់**រាយការណ៍ថា មានពលរដ្ឋខ្មែរចំនួន១២១នាក់ ត្រូវអាជ្ញាធរថៃឃាត់ខ្លួនពី បទឆ្លងដែនខុសច្បាប់ ហើយថៃឃាត់ខ្លួនលើសពីរយៈពេល១ខែមុននឹងបញ្ជូនមកកម្ពុជាវិញ។

- ❖ **ខេត្តបន្ទាយមានជ័យ** អាជ្ញាធរថៃបានបញ្ជូនពលករខ្មែរត្រឡប់មកប្រទេសកម្ពុជាវិញ ក្រោមរូបភាព «**និរទេស**» តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត សរុបមានចំនួន៩៩ជើង/រថយន្ត មានមនុស្សចំនួន៤.០៩០នាក់ (ស្រី១.៣៤១នាក់) ក្នុងនោះកុមារ៥១២នាក់ (កុមារី២៤១នាក់) **បើប្រៀបធៀបនឹងខែមុនមានការថយចុះ៩៩៣នាក់** ស្មើនឹង៣២.០៦%។ ក្រោយពីធ្វើការសម្ភាសរួច បានឲ្យយើងដឹងថា៖
  - ○ ចេញតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតចំនួន**១.៣៦៧**នាក់ តាមច្រករបៀងមាន**២.៧២៣**នាក់ ក្នុងនោះចេញដោយខ្លួនឯងមាន**១.៨០០**នាក់ និងតាមគេនាំមាន**២.២៩០**នាក់។
  - ○ សម្ភាសន៍កុមារចំនួន**១២៩**នាក់ (កុមារី៤៣នាក់) ពិនិត្យឃើញថាៈ ទៅតាមឪពុកម្តាយ**១០៣**នាក់ និងតាមបងប្អូន**២៦**នាក់។
- ❖ **ខេត្តបាត់ដំបង** ទទួលពលករខ្មែរ ដែលអាជ្ញាធរថៃចាប់បញ្ជូនមកវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិដូង ចំនួន០៥លើក មនុស្សចំនួន**៥៥**នាក់ ស្រី០៨នាក់។
- ❖ **ខេត្តប៉ៃលិន** ទទួលពលករខ្មែរ ដែលអាជ្ញាធរថៃចាប់បញ្ជូនមកវិញចំនួន**៣១**លើក មនុស្សចំនួន៣២៩នាក់ ស្រី១៣១នាក់។

• **ដោយឡែក យោងតាមរបាយការណ៍អគ្គនាយកដ្ឋានអន្តោប្រវេសន៍** បានរកឃើញជនបរទេសដែលមកធ្វើនៅក្នុងប្រទេសកម្ពុជាដោយខុសច្បាប់ និងត្រូវបណ្តេញចេញដោយមូលហេតុៈ

- **ឆ្លងដែន និងស្នាក់នៅខុសច្បាប់** ចំនួន៣៩លើក មនុស្សចំនួន១៧៩នាក់ (ស្រី០៥នាក់) មាន១១សញ្ជាតិ ក្នុងនោះ៖(ចិន១៣៦នាក់, វៀតណាម១៨នាក់ ស្រី០៥នាក់, នីហ្សេរីយ៉ា០៩នាក់, ឥណ្ឌូនេស៊ី០៧នាក់, អង់គ្លេស០៣នាក់, សិង្ហបុរី០១នាក់, កាមេរ៉ូន០១នាក់, ឥណ្ឌា០១នាក់, អាមេរិក០១នាក់ តួកគី០១នាក់ និងនេប៉ាល់០១នាក់) ក្នុងករណីខាងលើ មុននឹងបញ្ជូនចេញទៅប្រទេស ដើមវិញត្រូវបានបោះត្រាហាមចូលប្រទេសកម្ពុជាលើលិខិតឆ្លងដែន។
- **ការត្រួតពិនិត្យតាមសហគ្រាស និងគ្រឹះស្ថាននានា តាមបណ្តារាជធានី/ខេត្ត** បានចំនួន២៨៩គោលដៅ ពលករបរទេសចំនួន១.៤៤៩នាក់ ស្រី៤៦២នាក់ មាន១៦សញ្ជាតិ៖ **មានប័ណ្ណការងារៈ** ចំនួន១.៣៧៣នាក់ ផាកពិន័យចំនួន១៥ក្រុមហ៊ុន និង**គ្មានប័ណ្ណការងារៈ** ចំនួន២៨នាក់ ពិន័យជាប្រាក់ចំនួន១៤.០០០.០០០រៀល (ដប់បួនលានរៀលគត់)។

### ខ.៦-ការបង្ការ ទប់ស្កាត់ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍ខ្មែរនិងជនបរទេស

អគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) បានធ្វើការសម្ភាសពលរដ្ឋខ្មែរ និងជនបរទេសចំនួន**១៥៥**គូ ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់។ បានទំនាក់ទំនងនារីខ្មែរដែលទៅរស់នៅជាមួយស្វាមីឯក្រៅប្រទេសតាមរយៈទូរស័ព្ទផ្ទាល់ ដើម្បីតាមដានស្ថានភាពដែលសង្ស័យថាអាចកើតមានការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍ (រស់នៅជាមួយគ្រួសារសុខសប្បាយជាធម្មតា)។

## គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### គ.១ ការងារអនុវត្តច្បាប់

#### គ.១.១-<u>ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ</u>

អគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត និងកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានខិតខំតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ

បានចំនួន១២/១៨ករណី (ប្រៀបធៀបនឹងខែមុនថយចុះ០៦ករណី) ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន១៣នាក់ (ស្រី០៤នាក់) ក្នុងនោះជនសង្ស័យជាអនីតិជន០១នាក់ និងជនបរទេស០១នាក់(សញ្ជាតិឆេក) យើងបានសង្គ្រោះជនរងគ្រោះចំនួន២១នាក់ ក្នុងនោះអាយុក្រោម១៥ឆ្នាំ០៨នាក់ អាយុពី១៥-១៧ឆ្នាំ០៣នាក់ និងអាយុ១៨ឆ្នាំឡើង១០នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ចចំនួន១០នាក់ និងគ្រួសារចំនួន១១នាក់)។

**១. ករណីអំពើជួញដូរមនុស្ស៖**

បង្ក្រាបបាន០២/០៨ករណី (ថយចុះ០៤ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន០៣នាក់ (ជនបរទេសសញ្ជាតិឆេក០១នាក់) ស្រី០២នាក់ ជនរងគ្រោះចំនួន០៣នាក់ អាយុក្រោម១៥ឆ្នាំ០១នាក់ និងអាយុ១៨ឆ្នាំឡើង០២នាក់ (ប្រគល់ឲ្យគ្រួសារទាំងអស់) ដូចមានរាយលម្អិតក្នុងតារាងខាងក្រោម៖

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|
| -ការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅ | ១ | ១ | |
| -អំពើលក់-ដូរមនុស្សសម្រាប់នាំឆ្លងដែន | ១ | ២ | |
| *សរុប* | *០២ករណី* | *០៣នាក់* | |

**២.អំពើធ្វើអាជីវកម្មផ្លូវភេទ៖**

បង្ក្រាបបាន១០/១០ករណី ឃាត់ខ្លួនជនសង្ស័យចំនួន១០នាក់ (សញ្ជាតិឆេក០១នាក់) ស្រី០២នាក់ ជនរងគ្រោះចំនួន១៨នាក់ អាយុក្រោម១៥ឆ្នាំ០៨នាក់ អាយុ១៥-១៧ឆ្នាំ០២នាក់ និងអាយុ១៨ឆ្នាំឡើង០៨នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ច១០នាក់ និងគ្រួសារ០៨នាក់) ដូចមានរាយលម្អិតក្នុងតារាងខាងក្រោម៖

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|
| -សញ្ចារកម្ម | ១ | ១ | |
| -សញ្ចារកម្ម (មានអនីតិជន) | ១ | ១ | |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ៨ | ៨ | ឆេក១ |
| *សរុប* | *១០ ករណី* | *១០ នាក់* | *០១ នាក់* |

## ឃ.កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

**ឃ.១-ការសម្ភាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និងផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញារងគ្រោះ និងជនសង្ស័យ**

- យោងស្ថិតិ **ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ** បានបញ្ជូនពលរដ្ឋខ្មែរតាមរយៈ ស្ថានទូតស្ថានតំណាងនៅបរទេស ដែលសង្ស័យរងគ្រោះដោយអំពើជួញដូរមនុស្ស មានចំនួន៣៣នាក់ ស្រី១៨នាក់ មកពី៖
  - ប្រទេសម៉ាឡេស៊ី ចំនួន២២នាក់ ស្រី១២នាក់
  - ប្រទេសថៃ ចំនួន០៩នាក់ ស្រី០៤នាក់
  - ប្រទេសវៀតណាម ចំនួន០២នាក់ (ស្រី)។

*ស្ថាប័ន អង្គភាពអនុវត្តមាន៖*

- **អគ្គស្នងការដ្ឋាននគរបាលជាតិ** (របាយការណ៍តាមក្រុមការងារអនុវត្តន៍ច្បាប់) បានធ្វើសម្ភាសន៍ពលករ រងគ្រោះចំនួន០៩នាក់(ស្រី) ក្នុងនោះមកពីប្រទេសវៀតណាម០៤នាក់ ប្រទេសចិន០៣នាក់ និងម៉ាឡេស៊ី០២នាក់ តាមការសម្ភាសជនរងគ្រោះទៅតាមរយៈមេខ្យល់ទាំងអស់។

**ឃ.២-ការទទួលជនសង្ស័យរងគ្រោះ**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនិតិសម្បទា **(ក្រុមការងារការពារជនរងគ្រោះ)** ដោយមានកិច្ចសហការ ជាមួយអង្គការ IOM អង្គការចាប់ដៃ និងអង្គការរតនៈអ៊ិនជើនេសិនណល បានទទួលជនរងគ្រោះ និងងាយរងគ្រោះដោយ អំពើជួញដូរមនុស្ស មាតុភូមិនិវត្តន៍ប្រទេសនានា សរុបចំនួន១៨នាក់ ស្រី១៦នាក់ (កុមារី០១នាក់) មានដូចជាៈ ប្រទេសម៉ាឡេស៊ី០៣នាក់(ស្រី០២នាក់ កុមារី០១នាក់) វៀតណាម១៤នាក់(ស្រី១៣នាក់) និងចិន០១នាក់(ស្រី)។

**ឃ.៣-ការជួយជនរងគ្រោះ និងជនងាយរងគ្រោះ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស**

- **សមាហរណកម្មជនរងគ្រោះ**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (**ក្រុមការងារការពារជនរងគ្រោះ**) និងមន្ទីរសង្គមកិច្ច រាជធានី-ខេត្ត បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការមូលនិធិហាការអន្តរជាតិ បានសមាហរណកម្ម ជនរងគ្រោះដោយអំពើជួញដូរ ទៅតាមសហគមន៍វិញចំនួន០៤នាក់(ស្រី)។

## III. ការលើកកម្ពស់សមត្ថភាព

### ១. ក្នុងប្រទេស

**១.១-ការបណ្តុះបណ្តាល**

អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានសហការជាមួយជំនាញតាមក្រសួង មន្ទីរ អង្គភាព និងអង្គការដៃគូ បើកវគ្គបណ្តុះបណ្តាល បានចំនួន១៦វគ្គ មានសិក្ខាកាមចូលរួមចំនួន៧០៧នាក់ ក្នុងនោះមានស្ត្រី២៨៥នាក់ ដើម្បីពង្រឹងសមត្ថភាព គ្រូបង្គោល មន្ត្រីអនុវត្តន៍ច្បាប់ សមាជិកគ.ខ.ប.ជ លោកគ្រូ អ្នកគ្រូ និងប្រជាពលរដ្ឋ មានតារាងលម្អិតខាងក្រោម៖

***តារាងវគ្គបណ្តុះបណ្តាល***

| ល.រ | ស្ថាប័នអនុវត្ត និងវគ្គបណ្តុះបណ្តាល | ចំនួនវគ្គ | សិក្ខាកាម សរុប | សិក្ខាកាម នារី |
|---|---|---|---|---|
| ១ | **ខេត្តកោះកុង** បើកវគ្គបណ្តុះបណ្តាល៖<br>- ស្តីពីការទប់ស្កាត់ការរំលោភបំពានផ្លូវភេទលើស្ត្រី និងកុមារ ដល់ប្រជាពលរដ្ឋ ក្នុងភូមិ ៤ សង្កាត់ដងទង់ ក្រុងខេមរភូមិន្ទ អ្នកចូលរួមចំនួន៤៥នាក់ ស្រី៣៨នាក់។<br>- ស្តីពីការរំលោភបំពាន ការជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព នៅឃុំ ដងពែង ស្រុកស្រែអំបិល អ្នកចូលរួមចំនួន៥១នាក់ ស្រី៣៥នាក់។ | ០២ | ៩៦ | ៦៣ |
| ២ | **ខេត្តសៀមរាប** លេខាធិការដ្ឋាន គ.ខ.ប.ជ បើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាព ដល់មន្ត្រីនៅថ្នាក់ឃុំ សង្កាត់ ក្រុង ស្រុកទូទាំងខេត្ត ចំនួន១០ក្រុង ស្រុក។ | ១០ | ៤១៦ | ១៥៧ |
| ៣ | **ខេត្តកំពង់ធំ** លេខាធិការដ្ឋាន គ.ខ.ប.ជ បើកវគ្គបណ្តុះបណ្តាលស្តីពីការធ្វើចំណាក ស្រុកដោយសុវត្ថិភាព។ | ១ | ៥០ | ៣០ |
| ៤ | **ខេត្តឧត្តរមានជ័យ** បើកវគ្គបណ្តុះបណ្តាលដល់ គ.ក.ន.ក និងមន្ត្រីពាក់ព័ន្ធថ្នាក់ក្រុង ស្រុក ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងកិច្ចការពារជនរងគ្រោះ ដោយអំពើកេង ប្រវ័ញ្ចនានា។ | ៣ | ១៤៥ | ៣៥ |
| | *សរុប* | *១៦វគ្គ* | *៧០៧នាក់* | *២៨៥នាក់* |

**១.២-សិក្ខាសាលា៖**

លេខាធិការដ្ឋាន គ.ខ.ប.ជ បានសហការជាមួយអង្គការដៃគូ ដោយមានការសម្របសម្រួល ពីអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានរៀបចំសិក្ខាសាលា ប្រធានបទសំខាន់ផ្ដោតទៅលើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មានដូចខាងក្រោម ៖

- **ខេត្តកណ្ដាល** មន្ទីរទេសចរណ៍ខេត្ត បានសហការជាមួយក្រសួងទេសចរណ៍ និងអង្គការ Friend International បើកវគ្គសិក្ខាសាលា ស្ដីពី "**សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍**" ដល់មន្ត្រីនគរបាលទេសចរណ៍ អាជីវកម្មផ្ទះសំណាក់ សណ្ឋាគារ ខារ៉ាអូខេ ភោជនីយដ្ឋាន សរុបចំនួន៩០នាក់ ស្រី៥០នាក់។

**១.៣-កិច្ចប្រជុំការងារដឹកនាំសម្របសម្រួល៖**

ដោយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ ចំនួន**១៧**លើក ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាចំនួន០១លើក និងលេខាធិការដ្ឋាន រាជធានី-ខេត្តចំនួន**២៩**លើក សរុបកិច្ចប្រជុំ ស្ដីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សទូទាំងប្រទេសបាន**៤៧**លើក ដោយមានអ្នកចូលរួម**៩០០**នាក់ ស្រី៤១៤នាក់។ (**ឧបសម្ព័ន្ធទី២**)

## ២. ក្រៅប្រទេស

**២.១.ចូលរួមវគ្គបណ្ដុះបណ្ដាល៖**

- **អគ្គនាយកដ្ឋានអន្តោប្រវេសន៍** ចាត់បញ្ជូនមន្ត្រីនិងនាយនគរបាល**៣១រូប** ទៅចូលរួមវគ្គបណ្ដុះបណ្ដាល៖
  - ជំនាញច្រកទ្វារ នៅសាលាមធ្យមព្រំដែន២ ក្រុងវ៉ុងតាវ ខេត្តបារៀ ប្រទេសវៀតណាម។
  - ស្ដីពីការត្រួតពិនិត្យឯកសារសន្តិសុខ នៅទីក្រុងបាលី ប្រទេសឥណ្ឌូនេស៊ី។

**២.២.ចូលរួមសិក្ខាសាលា៖**

- **អគ្គនាយកដ្ឋានអន្តោប្រវេសន៍** ចាត់បញ្ជូននាយនគរបាល**០២រូប** ចូលរួមសិក្ខាសាលាសហការករណីរត់ពន្ធជនអន្តោប្រវេសន៍ក្នុងតំបន់ និងការជួញដូរមនុស្ស នៅទីក្រុងបាងកក ប្រទេសថៃ។

**២.៣.ចូលរួមកិច្ចប្រជុំ**

- លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំថ្នាក់តំបន់អាស៊ី-ប៉ាស៊ីហ្វិក ស្ដីពីកិច្ចព្រមព្រៀងសកលលើសុវត្ថិភាព សណ្ដាប់ធ្នាប់ទេសន្តប្រវេសន៍ស្របច្បាប់ នៅមជ្ឈមណ្ឌលសន្និសីទអង្គការសហប្រជាជាតិទីក្រុងបាងកក ប្រទេសថៃ។
- **អគ្គនាយកដ្ឋានអន្តោប្រវេសន៍** ចាត់បញ្ជូននាយនគរបាល**០៥រូប** ដើម្បីចូលរួម៖
  - សន្និសីទសាកល ស្ដីពីបទល្មើសឆ្លងដែន នៅទៅក្រុងសេអ៊ូល នៃសាធារណៈរដ្ឋកូរ៉េ។
  - វេទិកាប្រធានច្រកទ្វារអន្តោប្រវេសន៍លើកទី២ នៅទីក្រុង Tangerang ខេត្តBanten ប្រទេសឥណ្ឌូនេស៊ី។
  - ដើម្បីធ្វើការសម្ភាស និងកំណត់អត្តសញ្ញាណពលរដ្ឋខ្មែរចំនួន១០០នាក់ ទៅទីក្រុងអាឌែលឡែនតូ រដ្ឋកាលីហ្វ័រញ៉ា សហរដ្ឋអាមេរិក។

# IV. ការសន្និដ្ឋានវាយតម្លៃ

## ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សម្រេចការងារជាលទ្ធផលជាគជ័យគួរកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្ដល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិផងដែរ។
- ការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្ដល់អនុសាសន៍ **០៤ចំណុច** និងវិធានការ **០៦ចំណុច** របស់សម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន គ.ជ.ប.ជ គឺជាប្រទីបដ៏ល្អដល់គ.ជ.ប.ជ និងគ្រប់សមាសភាពដែលជាយន្តការក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- យើងមានច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។
- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារនេះ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួងស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

## ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង និងចំណុចខ្លាំងខាងលើ យើងពិនិត្យឃើញនៅមានចំណុចប្រឈម នឹងសេសសល់មួយចំនួនដូចជា ៖

- ថ្វីត្បិតតែយើងបានបង្កើតក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួននៅមិនទាន់ចេះសហការគ្នា ជាប្រព័ន្ធនិងបែងចែកការទទួលខុសត្រូវបន្តរហូតចប់ការងារ។
- ការធ្វើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងឲ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស។
- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណា ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ។
- របាយការណ៍សំខាន់ណាស់សម្រាប់ក្រសួង ស្ថាប័ន អង្គភាពបើរបាយការណ៍ល្អ នោះបញ្ជាក់ថាក្រសួង ស្ថាប័ន ឬអង្គភាពនោះមានស្នាដៃ សកម្ម ហើយកិត្តិយសក្រសួង ស្ថាប័ន អង្គភាពក៏បានល្អដែរ។ ឧទាហរណ៍ ក្រសួង ស្ថាប័ន ឬអង្គភាព បានធ្វើការងារច្រើនទាក់ទងនឹងការងារអំពើជួញដូរមនុស្ស តែមន្ត្រីធ្វើរបាយការណ៍មិនយល់ ឬមិនបានសរសេរអស់នូវសកម្មភាព និងទិន្នន័យដែល ក្រសួង ស្ថាប័ន ឬអង្គភាពខ្លួនបានធ្វើ ដូច្នេះកិត្តិយស ក្រសួង ស្ថាប័ន អង្គភាពនោះក៏មិនអស់តាមរបាយការណ៍នោះដែរ។

## គ.សំណូមពរ

➢ គ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជនត្រូវយកចិត្តទុកដាក់ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន។

- វគ្គបណ្តុះបណ្តាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឲ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។
- ក្រសួង ស្ថាប័ន អង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់អនុវត្តតាមសេចក្តីសម្រេចស្តីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលប្រធាន គ.ជ.ប.ដ បានសម្រេច។

### ឃ. សន្និដ្ឋាន

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង ៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ដ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។
- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឲ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារៈ និងការចងក្រងលិខិតបទដ្ឋានគតិយុត្តិនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។
- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយអ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន នោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាមិនខាន។

## V. ទិសដៅឆ្នាំ ឆ្នាំ២០១៧

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឲ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួមដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព។

២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់រូបភាពជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ការដកហូតសរីរាង្គជួញដូរ ការរត់ពន្ធទារក និងកុមារឆ្លងដែន ការពពោះជំនួស និងការជួញដូរពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។ល។

៣. រៀបចំផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(ពាក់កណ្តាលអាណត្តិទី២៖២០១៧-២០១៨)។

៤. ត្រៀមចុះហត្ថលេខាលើកិច្ចព្រមព្រៀងទ្វេភាគីកម្ពុជា-ឥណ្ឌា និងជាមួយប្រទេសពាក់ព័ន្ធដទៃទៀត។

៥. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌។

៦. គាំទ្រ និងពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត។

៧. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឲ្យបានដល់ប្រជាពលរដ្ឋ ជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។

៨. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាល មន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។

៩. បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សដែល សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥។

១០. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឲ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឲ្យបានត្រឹមត្រូវ។

១១. បន្តរៀបចំវិធានការ "**គ្រប់គ្រងលំហូរ ពលករទេសន្តរប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី**" (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ )។

១២. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។

១៣. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ។

**ទិសដៅបន្ថែម ដែលជាអនុសាសន៍សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងកិច្ចប្រជុំឆមាសទី១ នេះ ដែលគប្បីជំរុញអនុវត្ត ឲ្យមានប្រសិទ្ធភាព សម្រាប់ដំណាក់កាលដ៏ចាំបាច់៖**

១៤. ជំរុញអនុវត្តវិធានការ ដែលដាក់ចុះដោយក្រសួងមហាផ្ទៃ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងការបរទេស ក្នុងដំណាក់កាលនៃការជំរុញដំណោះស្រាយភាពស្របច្បាប់ដល់ពលករ ដែលនៅក្នុងប្រទេសថៃ និងការទទួលខុសត្រូវរបស់អាជ្ញាធរ សមត្ថកិច្ចពាក់ព័ន្ធ ក្នុងការជួយដល់ពលករដែលត្រូវបានបញ្ជូនត្រឡប់។

១៥. បង្កើតក្រុមការងារ ពិសេសមួយក្រោមគណៈកម្មការផ្តល់ភាពស្របច្បាប់ ដឹកនាំដោយរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីស្រាវជ្រាវ អំពីពលករខ្មែរ ដែលមានវត្តមានក្នុងប្រទេសថៃ ស្ថានភាពស្របច្បាប់ ឬមិនស្របច្បាប់ ទីកន្លែងធ្វើការ អាស័យដ្ឋាននៅកម្ពុជា ដើម្បីងាយស្រួល ក្នុងការដោះស្រាយបញ្ហា និងទំនាក់ទំនងអប់រំ ផ្តល់សេវា និងបង្កើនភាពជឿជាក់ដល់រាជរដ្ឋាភិបាល។

១៦. រៀបចំបែងចែកក្រុមនេះ ដោយស្នើសុំបញ្ចូលជាក្រុមដែលមានបេសកកម្មពិសេស ជាអនុព័ន្ធការងារ ក្នុងរយៈពេលខ្លីមួយ ដែលនឹងត្រូវរំសាយវិញ ពេលចប់បេសកកម្ម។

១៧. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃ នៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្ន មុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬ នៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម។

ថ្ងៃ.....................ខែ..............នព្វស័ក ព.ស ២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី..........ខែ..........ឆ្នាំ២០១៧

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជូ-ប៊ុនអេង**

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

**"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"**

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន

-សមាជិកក្រុមការងារ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

**"ដើម្បីជូនជ្រាប"**

-ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធទី១

## សកម្មភាពផ្សព្វផ្សាយ និងវេទិកាសាធារណៈក្នុងខែវិច្ឆិកា ឆ្នាំ២០១៧

| ល.រ | របាយការណ៍ពី | ខ្លឹមសារសកម្មភាព | អង្គភាព-ស្ថាប័នអ្នករៀបចំ | ចំនួនលើក | ចំនួនមនុស្ស | ចំនួនស្រី |
|---|---|---|---|---|---|---|
| 1 | ក្រុមការងារអនុវត្តន៍ច្បាប់ | ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ផ្សព្វផ្សាយច្បាប់ ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងភូមិ-ឃុំមានសុវត្ថិភាព ដល់អាជ្ញាធរមូលដ្ឋាន ប្រជាពលរដ្ឋ លោកគ្រូ-អ្នកគ្រូ និងសិស្សានុសិស្ស។ | ស្នងការដ្ឋាននគរបាលខេត្ត | 703 លើក | 82,623 នាក់ | 42,139 នាក់ |
| 2 | ខេត្តតាកែវ | ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ស្តីពីការទប់ស្កាត់ការជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព។ | លេខាធិការដ្ឋាន គ.ខ.ប.ជ មន្ទីរកិច្ចការនារីខេត្ត | 2 លើក | 75 នាក់ | |
| 3 | ខេត្តពោធិ៍សាត់ | វេទិកាសាធារណៈ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងអំពើជួញដូរមនុស្ស ដល់ប្រជាពលរដ្ឋ នៅក្រុងពោធិ៍សាត់ ស្រុកក្រគរ ស្រុកភ្នំក្រវាញ និងស្រុកបាកាន។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 242 លើក | 47,305 នាក់ | 20,253 នាក់ |
| | | ផ្សព្វផ្សាយតាមរយៈភូមិ-ឃុំមានសុវត្ថិភាព ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ នៅក្រុងពោធិ៍សាត់ ស្រុកក្រគរ ស្រុកកណ្តៀង ស្រុកភ្នំក្រវាញ និងស្រុកបាកាន។ | ស្នងការដ្ឋាននគរបាលខេត្ត | 15 លើក | 859 នាក់ | 411 នាក់ |
| 4 | ខេត្តបាត់ដំបង | ផ្សព្វផ្សាយ ស្តីពី ការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការ និងប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 1,345 លើក | 83,986 នាក់ | 44,771 នាក់ |
| | | វេទិកាសាធារណៈ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្សលើស្ត្រី និងកុមារ ការធ្វើអាជីវកម្មផ្លូវភេទ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការ និងប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 696 លើក | 24,690 នាក់ | 12,786 នាក់ |
| 5 | ខេត្តស្វាយរៀង | វេទិកាសាធារណៈ ស្តីពីទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 307 លើក | 19,514 នាក់ | 5,246 នាក់ |
| | | ផ្សព្វផ្សាយដល់ពលករ ពលការិនី ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព នៅរោងចក្រ DK inc តំបន់សេដ្ឋកិច្ចពិសេសតាយសេង។ | មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត | 1 លើក | 20 នាក់ | 11 នាក់ |
| 6 | ខេត្តក្រចេះ | ផ្សព្វផ្សាយ ស្តីស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស កិច្ចការពារជនរងគ្រោះ និងការធ្វើចំណាកស្រុក ដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 1 លើក | 53 នាក់ | 16 នាក់ |
| 7 | ខេត្តសៀមរាប | ផ្សព្វផ្សាយ ស្តីពីការប្រឆាំងអំពើជួញដូរមនុស្ស នៅសកលវិទ្យាល័យខេត្ត ដល់និស្សិត។ | កងរាជអាវុធហត្ថខេត្ត | 1 លើក | 75 នាក់ | 25 នាក់ |

| | | | | | | |
|---|---|---|---|---|---|---|
| 8 | ខេត្តកំពង់ចាម | ផ្សព្វផ្សាយ ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការនគរបាលខេត្ត និងអង្គការសម្ព័ន្ធចាប់ដៃ | 707 លើក | 83,657 នាក់ | 43,239 នាក់ |
| 9 | ខេត្តត្បូងឃ្មុំ | វេទិកាសាធារណៈ ស្ដីពីទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ការិយាល័យប្រឆាំងការជួញដូរមនុស្ស នៃស្នងការខេត្ត | 33 លើក | 227 នាក់ | 86 នាក់ |
| | | ផ្សព្វផ្សាយ ស្ដីពីការងារបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 6 លើក | 246 នាក់ | 193 នាក់ |
| 10 | ខេត្តប៉ៃលិន | ផ្សព្វផ្សាយច្បាប់ ស្ដីពីការប្រឆាំងអំពើជួញដូរមនុស្ស និងទប់ស្កាត់ការធ្វើចំណាកស្រុកដោយប្រថុយប្រថាន តាមរយៈកិច្ចប្រជុំរបស់ គ.ក.ស.ក តាមសាលារៀន សហគមន៍មូលដ្ឋាន ឃុំ សង្កាត់។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 10 លើក | 329 នាក់ | 120 នាក់ |
| 11 | ខេត្តកែប | ផ្សព្វផ្សាយច្បាប់ស្ដីពី ការទប់ស្កាត់អំពើជួញដូរមនុស្ស អំពើរំលោភបំពានផ្លូវភេទលើស្ត្រីនិងកុមារ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងកិច្ចការពារជនរងគ្រោះ ដល់ប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 5 លើក | 671 នាក់ | 334 នាក់ |
| | | ផ្សព្វផ្សាយការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមរយៈវេទិកាផ្សព្វផ្សាយស្ដីពីគោលនយោបាយភូម-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | | 388 លើក | 73,544 នាក់ | 37,629 នាក់ |
| 12 | ខេត្តកោះកុង | វេទិកាសាធារណៈ ស្ដីពីទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 26 លើក | 1,599 នាក់ | 83 នាក់ |
| | | ផ្សព្វផ្សាយ ស្ដីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងបញ្ជ្រាបពីការជួញដូរមនុស្ស ក្នុងពិធីបើកបវេសនកាលនៅតាមវិទ្យាល័យ ដល់លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស មន្ត្រីរាជការ និងប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ មន្ទីរអប់រំយុវជន និងកីឡា | 6 លើក | 3,010 នាក់ | |
| 13 | ខេត្តកណ្ដាល | វេទិកាសាធារណៈ ស្ដីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 511 លើក | 78,729 នាក់ | 27,300 នាក់ |
| | | ផ្សព្វផ្សាយ ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព កិច្ចការពារជនរងគ្រោះ ដល់ប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 45 លើក | 1,556 នាក់ | 936 នាក់ |
| 14 | កំពង់ផ្ទាំង | វេទិកាសាធារណៈផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ នូវច្បាប់ស្ដីពីអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព។ | ស្នងការដ្ឋាននគរបាលខេត្ត | 429 លើក | 14,501 នាក់ | 8,967 នាក់ |
| | | ផ្សព្វផ្សាយលក្ខណៈសម្បត្តិ៩យ៉ាង អំពីគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ស្ដីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងអំពើជួញដូរមនុស្ស ដល់ប្រជាពលរដ្ឋ ។ | ស្នងការដ្ឋាននគរបាលខេត្ត ក្រុមការងារថ្នាក់ភូមិ ស្រុក | 388 លើក | 13,465 នាក់ | 8,137 នាក់ |

| | | | | | | |
|---|---|---|---|---|---|---|
| 15 | **ខេត្តព្រះវិហារ** | ផ្សព្វផ្សាយ ស្តីពីការងារបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | មន្ទីរកិច្ចការនារីខេត្ត | 3 លើក | 491 នាក់ | 319 នាក់ |
| 16 | **ខេត្តកំពង់ធំ** | ផ្សព្វផ្សាយ ច្បាប់ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កិច្ចការពារជនរងគ្រោះ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់អាជ្ញាធរមូលដ្ឋាន លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 5 លើក | 924 នាក់ | 248 នាក់ |
| 17 | **ខេត្តកំពង់ស្ពឺ** | ផ្សព្វផ្សាយច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ និងកិច្ចការពារជនរងគ្រោះ ដល់ប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ និង អង្គការពាក់ព័ន្ធ | 4 លើក | 512 នាក់ | 206 នាក់ |
| 18 | **ខេត្តព្រៃវែង** | ផ្សព្វផ្សាយច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ និងការធ្វើចំណាកស្រុក ដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ការិយាល័យប្រឆាំងការជួញដូរមនុស្ស នៃស្នងការខេត្ត | 1 លើក | 21 នាក់ | 11 នាក់ |
| 19 | **ខេត្តឧត្តរមានជ័យ** | ផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ដល់លោកគ្រូ អ្នកគ្រូ សិស្សានុសិស្សនិងប្រជាពលរដ្ឋក្នុងមូលដ្ឋាន។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 1 លើក | 38 នាក់ | 20 នាក់ |
| 20 | **ខេត្តរតនគិរី** | វេទិកាសាធារណៈ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 2 លើក | 179 នាក់ | 74 នាក់ |
| 21 | **ខេត្តព្រះសីហនុ** | ផ្សព្វផ្សាយ ស្តីពីទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ អាជ្ញាធរ ភូមិ ក្រុមប្រឹក្សាឃុំ/សង្កាត់ លោកគ្រូ អ្នកគ្រូ និងប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ និង មន្ទីរកិច្ចការនារីខេត្ត | 5 លើក | 651 នាក់ | 325 នាក់ |

**សកម្មភាពសរុបចំនួន:** 5,888 លើក

**មនុស្សសរុបចំនួន:** 533,550 នាក់

**ស្រីសរុបចំនួន :** 253,885 នាក់

## ឧបសម្ព័ន្ធទី២

## តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន៤៧លើក) មនុស្សចំនួន៩០០នាក់ (ស្រី៤១៤នាក់)

| ស្ថាប័ន សម្របសម្រួល | សកម្មភាព |
|---|---|
| គណៈកម្មាធិការជាតិ គ.ជ.ប.ជ | **សម្របសម្រួលចំនួន១៧លើក អ្នកចូលរួមសរុបចំនួន២៩៤នាក់ (ស្រី១០៤នាក់)**<br>- បានដឹកនាំកិច្ចប្រជុំពិភាក្សាអន្តរក្រសួង រៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០១៧ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន មានសមាសភាពចូលរួមចំនួន៥៦នាក់ ស្រី១៧នាក់។<br>- បានអញ្ជើញចូលរួមកិច្ចប្រជុំក្រសួងមហាផ្ទៃ ស្តីពីសភាពការណ៍បច្ចុប្បន្ន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- បានដឹកនាំកិច្ចប្រជុំជាមួយថ្នាក់ក្រោមជាតិ ត្រួតពិនិត្យរបាយការណ៍ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១០ខែ ឆ្នាំ២០១៧ នៅទីស្តីកាក្រសួងមហាផ្ទៃ មានសមាស ភាពចូលរួមចំនួន១០៩នាក់ ស្រី៥៨នាក់។<br>- បានដឹកនាំកិច្ចប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ស្តីពីសភាពការណ៍បច្ចុប្បន្ន នៅសាលប្រជុំអគ្គលេខាធិការ អ្នកចូលរួមចំនួន៦៧នាក់ ស្រី១១នាក់។<br>- បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុង ស្តីពីការងារវិភាគមុខងារមន្ត្រី នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន (**០៥លើក**)។<br>- បានដឹកនាំប្រជុំពិភាក្សាការងារជាមួយទូរទស្សន៍ PNN និង BTV ស្តីពីបទយកការណ៍សម្រាប់បង្ហាញនៅថ្ងៃទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ២០១៧ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន អ្នកចូលរួមចំនួន១៤នាក់ ស្រី០៥នាក់។<br>- បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុង ស្តីពីការងារវិភាគមុខងារ វឌ្ឍនៈភាពការងារនិងបញ្ហាប្រឈមនានារបស់អគ្គលេខាធិការដ្ឋាន នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន មានអ្នកចូលរួមចំនួន១៦នាក់ ស្រី០៣នាក់។<br>- បានដឹកនាំប្រជុំពិភាក្សាការងារជាមួយតំណាងអង្គការ IJM ដឹកនាំដោយលោក Peter Williams នាយកប្រតិបត្តិប្រចាំកម្ពុជា នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន មានសមាសភាពចូលរួមចំនួន២៣នាក់ ស្រី០៨នាក់។<br>- បានដឹកនាំប្រជុំពិភាក្សាការងារជាមួយទូរទស្សន៍ PNN និង BTV ស្តីពីបទយកការណ៍សម្រាប់បង្ហាញនៅថ្ងៃទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ២០១៧ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន មានសមាសភាពចូលរួម០៩នាក់ ស្រី០២នាក់។<br>- បានដឹកនាំកិច្ចប្រជុំគណៈកម្មការសិល្បៈ ត្រៀមរៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០១៧ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន។<br>- បានអញ្ជើញចូលរួមកិច្ចប្រជុំក្រសួងមហាផ្ទៃ ស្តីពីសភាពការណ៍បច្ចុប្បន្ន នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- បានចូលរួមប្រជុំក្រុមការងារបច្ចេកទេស នៃគណៈកម្មការការពារកុមារថ្នាក់ជាតិ ស្តីពីការបង្កើតគោលនយោបាយជាតិស្តីពីប្រព័ន្ធការពារកុមារ នៅភោជនីយ៍ |

| | |
|---|---|
| | ដ្ឋានទន្លេបាសាក់២។<br>- បានអញ្ជើញចូលរួមប្រជុំ ស្តីពីរបាយការណ៍កុមារដាក់ជូនអង្គការសហប្រជាជាតិ នៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ |
| **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** | - ប្រជុំ ស្តីពីការចុះកិច្ចព្រមព្រៀងរវាងក្រសួងស.អ.យ និងអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ CWCC និងអង្គការសមាគមទឹកដីសន្យា (ផ្ទះនាងអេសធើ) អ្នកចូលរួមចំនួន២៨នាក់ ស្រី១១នាក់។ |
| **លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន២៩លើក អ្នកចូលរួមសរុបចំនួន៥៧៨នាក់ (ស្រី២៩៩នាក់)** | |
| **ខេត្តព្រះវិហារ** | **សម្របសម្រួលចំនួន០២លើក អ្នកចូលរួមសរុបចំនួន២៣នាក់ (ស្រី០៩នាក់)**<br>- កិច្ចប្រជុំ ស្តីពីការបូកសរុបសកម្មភាព និងលទ្ធផលការងាររយៈពេល១០ខែ និងត្រៀមធ្វើរបាយការណ៍ប្រចាំ ឆ្នាំ២០១៧ និងពង្រឹងការងារអនុវត្តផែនការផ្សព្វផ្សាយការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ ឆ្នាំ២០១៧។<br>- ចូលរួមកិច្ចប្រជុំរៀបចំរបាយការណ៍ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៧ និងលើកទិសដៅឆ្នាំ២០១៨ នៅក្រសួងមហាផ្ទៃ។ |
| **ខេត្តបន្ទាយមានជ័យ** | - ប្រជុំបូកសរុបលទ្ធផលការងាររយៈពេល១០ខែ និងខែតុលា ឆ្នាំ២០១៧ នៅសាលប្រជុំក្រុមប្រឹក្សាខេត្តបន្ទាយមានជ័យ អ្នកចូលរួមចំនួន៤១នាក់ ស្រី១៤នាក់។ |
| **ខេត្តកំពត** | - ប្រជុំប្រចាំខែ ត្រួតពិនិត្យ និងកែសម្រួលរបាយការណ៍១០ខែ។ |
| **ខេត្តតាកែវ** | - ចូលរួមកិច្ចប្រជុំឆ្លងរបាយការ១០ខែ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅក្រសួងមហាផ្ទៃ។ |
| **ខេត្តសៀមរាប** | - លេខាធិការដ្ឋាន គ.ខ.ប.ជ ប្រជុំប្រចាំខែវិច្ឆិកា អ្នកចូលរួមចំនួន៣១នាក់ ស្រី១៧នាក់។ |
| **ខេត្តប៉ៃលិន** | - ចូលរួមកិច្ចប្រជុំឆ្លងរបាយការ១០ខែ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅក្រសួងមហាផ្ទៃ។ |
| **ខេត្តកំពង់ស្ពឺ** | - ចូលរួមកិច្ចប្រជុំឆ្លងរបាយការ១០ខែ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅក្រសួងមហាផ្ទៃ។<br>- ប្រជុំត្រួតពិនិត្យការងារគណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អ្នកចូលរួមចំនួន៦៥នាក់ ស្រី២៧នាក់។ |
| **ខេត្តព្រៃវែង** | - ប្រជុំប្រចាំខែវិច្ឆិកា និងពិភាក្សាអំពីទិវាប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ ឆ្នាំ២០១៧ អ្នកចូលរួមចំនួន៣៦នាក់ ស្រី១១នាក់។ |
| **ខេត្តកែប** | - ប្រជុំចំនួន០២លើក ដើម្បីពង្រឹងតួនាទី ភារកិច្ច របៀបរបបការងារ និងការបំពេញរបាយការណ៍របស់សមាសភាពនៃមន្ទីរ និងអង្គភាពពាក់ព័ន្ធ។<br>- ប្រជុំត្រួតពិនិត្យ និងការរៀបចំរបាយការណ៍ប្រចាំឆ្នាំ២០១៧។ |
| **ខេត្តកំពង់ចាម** | - ចូលរួមសិក្ខាសាលា ស្តីពីការប្រគល់មុខងារគ្រប់គ្រងមណ្ឌលថែទាំកុមាររបស់រដ្ឋ ត្រួតពិនិត្យមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល និងការគ្រប់គ្រងសេវាថែទាំកុមាររងគ្រោះ នៅក្នុងសហគមន៍ទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។<br>- ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទដែលស្នាក់នៅក្នុងមណ្ឌល និងបទដ្ឋានអប្បបរមាស្តីពីកិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្សនៅមន្ទីរសង្គមកិច្ច ខេត្តព្រះសីហនុ។ |
| **ខេត្តកំពង់ឆ្នាំង** | - ប្រជុំប្រជុំប្រចាំខែវិច្ឆិកា អ្នកចូលរួមចំនួន៦៥នាក់ ស្រី២៥នាក់។ |

| | |
|---|---|
| **ខេត្តកំពង់ធំ** | **សម្របសម្រួលចំនួន០៣លើក អ្នកចូលរួមសរុបចំនួន៥០នាក់ (ស្រី៣៧នាក់)**<br>- ចូលរួមកិច្ចប្រជុំឆ្លងរបាយការ១០ខែ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅក្រសួងមហាផ្ទៃ។<br>- ប្រជុំប្រចាំឆមាសទី២ និងកិច្ចប្រជុំឆ្លងរបាយការណ៍សម្រាប់ឆ្នាំ២០១៧ អ្នកចូលរួមចំនួន៣០នាក់។<br>- ប្រជុំផ្សព្វផ្សាយស្តីពីការធ្វើទេសន្តរប្រវេសន៍ អ្នកចូលរួមចំនួន២០នាក់ ស្រី០៧នាក់។ |
| **ខេត្តស្វាយរៀង** | - ប្រជុំត្រួតពិនិត្យការងាររយៈពេល១០ខែ ឆ្នាំ២០១៧ អ្នកចូលរួមចំនួន៤១នាក់ ស្រី២១នាក់។ |
| **ខេត្តកណ្តាល** | **សម្របសម្រួលចំនួន០៩លើក អ្នកចូលរួមសរុបចំនួន៣០៧នាក់ (ស្រី១៧៥នាក់)**<br>- ក្រុមការងារថ្នាក់ស្រុក រៀបចំកិច្ចប្រជុំខែវិច្ឆិកា ចំនួន០៧លើក អ្នកចូលរួមចំនួន១៥៤នាក់ ស្រី១០១នាក់។<br>- លេខាធិការដ្ឋានខេត្ត រៀបចំកិច្ចប្រជុំបូកសរុបការងារប្រចាំខែតុលា ដោយមានអ្នកចូលរួមក្រុមការងារខេត្ត និងស្រុកចំនួន៣០នាក់ ស្រី២២នាក់។<br>- ប្រជុំបូកសរុបការងារអប់រំយុវជន និងកីឡាខេត្ត ប្រចាំខែវិច្ឆិកា និងលើកទិសដៅការងារខែធ្នូ និងការប្រជុំការងារនៅក្នុងមន្ទីរអប់រំ អ្នកចូលរួមចំនួន១២៣នាក់ ស្រី៥២នាក់។ |
| **ខេត្តឧត្តរមានជ័យ** | - ចូលរួមប្រជុំ គ ក ស ក នៅសាលាខេត្ត អ្នកចូលរួមចំនួន២៥នាក់ ស្រី១១នាក់។ |